# I- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៤០ អនក្រ.បក

### ស្តីពី

### ការបង្កើត ទិវាជលយោធាទឹក កសិកម្ម

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម

-បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

**សំរេច**

មាត្រា ១ .-

បង្កើតទិវាប្រជាពលរដ្ឋចូលរួមធ្វើពលកម្មដោយស្ម័គ្រចិត្តលើការងារធារាសាស្ត្រ ហៅថា "ទិវាជលយោធាទឹកកសិកម្ម" ដែលត្រូវប្រារព្ធធ្វើនៅថ្ងៃទី០៤ មិនា ជារៀងរាល់ឆ្នាំ ។

មាត្រា ២ .-

ទិសដៅនៃទិវានេះ ជាសកម្មភាពប្រជាពលរដ្ឋពេញវ័យគ្រប់រូប ដែលអាចចូលរួមដោយស្ម័គ្រចិត្ត ពោលបំពេញដោះស្រាយទឹក ដើម្បីបំរើវិស័យកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋអោយកាន់តែប្រសើរឡើង ។

មាត្រា ៣ .-

ក្រសួងមហាផ្ទៃមានភារកិច្ចណែនាំអភិបាលខេត្ត-ក្រុង ជ្រើសរើសទីកន្លែងជាក់ស្តែងសំរាប់ការដ្ឋាន និងអំពាវនាវប្រជាពលរដ្ឋចូលរួម ព្រមទាំងរៀបចំបំរុងផ្នែកសំភារៈ បំរើអោយទិវានេះទទួលបានប្រសិទ្ធភាពនយោបាយ និងសេដ្ឋកិច្ចខ្ពស់ ។

មាត្រា ៤ .-

ក្រសួងធនធានទឹក និង ឧតុនិយម មានភារកិច្ចណែនាំបច្ចេកទេស និងសហការជាមួយមន្ទីរខេត្ត-ក្រុង ក្នុងការអនុវត្តន៍ ។

មាត្រា ៥ .-

អនុក្រឹត្យលេខ១០ អនក្រ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតទិវានយោបាយទឹក កសិកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃ ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ដើម្បីសូមហត្ថលេខា

រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម

**លឹម គានហោ**

★★★

**អនុក្រឹត្យ លេខ ៤១ អនក្រ.បក**

**ស្តីពី**

**ការផ្ទេរឥណទានថវិកា**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹតលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា